00893580

E270/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 03 / 2013
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខៈ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យូរ ឧត្តរា |
| កាលបរិច្ឆេទៈ | ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ |
| ភាសាដើមៈ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារៈ | សាធារណៈ |

# សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន
អៀង សារី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១ អង្គជំនុំជម្រះសាលាដំបូងបានទទួលលិខិតបញ្ជាក់មរណភាពរបស់ជនជាប់ចោទ អៀង សារី ពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣[1]។

## ២. ប្រវត្តិនីតិវិធី

២ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចោទប្រកាន់ នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និង កាំង ហ្គេកអ៊ាវ ហៅឌុច បានប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[2]។ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជនជាប់ចោទ អៀង សារី ត្រូវបានចាប់ខ្លួនដោយដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត និងបានបញ្ជូនមកមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ហើយបានជូនដំណឹងពីបទចោទប្រឆាំងនឹងជនជាប់ចោទរូបនេះ[3]។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចោទប្រកាន់ប្រឆាំងនឹង អៀង សារី នួន ជា ខៀវ សំផន អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការបំពារបំពាន ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[4]។ នៅក្នុងការសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានតម្កល់ទុកជាបានការ ដោយមានការសម្រេចកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយ

[1] លិខិតមរណភាពរបស់ អៀង សារី, ឯកសារ E270, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ឯកសារ D3, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានបំបែកនៅពេលក្រោយមកទៀត (ដីកាបំបែកសំណុំរឿង, ឯកសារ D18,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧)។

[3] ដីកាបង្គាប់ឱ្យឃុំខ្លួន អៀង សារី, ឯកសារ C23, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧; ដីកាដំណោះស្រាយ, ឯកសារ D427, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ៧, សេចក្ដីសម្រេចឃុំខ្លួន, ឯកសារ C14, ថ្ងៃទី ១២ វិច្ឆិកា ២០០៧។

[4] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦១៣។ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ជនជាប់ចោទចំពោះការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ នៅពេលក្រោយមកទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាដីកាដំណោះស្រាយបានខកខានពុំបានបញ្ជាក់អំពីការចោទប្រកាន់ទាំងនេះឱ្យបានជាក់លាក់គ្រប់គ្រាន់ និងបានណែនាំថាការចោទប្រកាន់ទាំងនេះពុំមែនជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះទៅថ្ងៃមុខក្នុងសំណុំរឿង០០២ឡើយ (សេចក្ដីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្ដី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ), ឯកសារ E122, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១)។

នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[5]។ អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្ដើមធ្វើសវនាការបឋម នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។ ជនជាប់ចោទ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា[6] ។

## ៣. សំអាងច្បាប់

៣ អនុលោមតាមមាត្រា ៧.១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មរណភាពរបស់ជនជាប់ចោទ អៀង សារី ត្រូវរលត់បណ្ដឹងអាជ្ញា ប្រឆាំងនឹងរូបគាត់នៅចំពោះមុខ អ.វ.ត.ក[7]។ អនុលោមតាមវិធាន ២៣ស្ទួន អនុវិធាន ៦ នៃវិធានផ្ទៃក្នុង មរណភាពរបស់ជនជាប់ចោទ ក៏បញ្ចប់បណ្ដឹងរដ្ឋប្បវេណីផងដែរ នៅ អ.វ.ត.ក[8]។

---

[5] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ (អ.ប.ជ), ឯកសារ D427/2/12, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ទំព័រ ៦ (ដោយបានធ្វើវិសោធនកម្មដីកាដំណោះស្រាយដើម្បីតម្រូវឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ និងបានអះអាងថាអំពើរំលោភសេពសន្ថវៈអាចត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌មួយទៀត)។ នៅពេលក្រោយមកទៀត អង្គជំនុំជម្រះសាលាដំបូងបានជំទាស់ទៅនឹងលក្ខខណ្ឌតម្រូវ នៃទំនាក់ទំនងនេះ (សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពី និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ឯកសារ E95/8, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ៣៣)។

[6] លិខិតមរណភាពរបស់ អៀង សារី, ឯកសារ E270, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[7] *សូមមើល* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (អ.ជ.ត.ក), E138/1/10/1/5/7, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២, កថា ខណ្ឌ ៣៨; *សូមមើលផងដែរ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Delić, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY (លេខសំណុំរឿង IT-04-83-A), សេចក្ដីសម្រេចស្ដីពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០, កថាខណ្ឌ ៥-១៥។ *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Karemera et al., អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (លេខសំណុំរឿង ICTR-98-44-T), សេចក្ដីសម្រេចទាក់ទងនឹងសារណារបស់ក្រឡាបញ្ជីដែលជូនដំណឹងអំពីការស្លាប់របស់ជនជាប់ចោទ Joseph Nzirorera, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០, កថាខណ្ឌ ២។ *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Kony et al., អង្គបុរេ ជំនុំ ជម្រះ នៃ តុលាការ ICC (លេខសំណុំរឿង ICC-02/04-01/05), សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង Raska Lukwiya, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧។ សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* Norman et al., អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ SCSL (លេខសំណុំរឿង SCSL-04-14-T), សេចក្ដីសម្រេចលើសារណារបស់ក្រឡាបញ្ជីស្ដីពីភស្តុតាងនៃការស្លាប់របស់ជនជាប់ចោទ Samuel Hinga Norman និងបញ្ហានាពេលបន្ទាប់, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៧, កថាខណ្ឌ ១៣-១៨។

[8] អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថាអនុលោមតាមមាត្រា ២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មរណភាពរបស់ជនជាប់ចោទមិនអាចបញ្ចប់បណ្ដឹងរដ្ឋប្បវេណីដែលប្រឆាំងនឹងគាត់បានឡើយ។ បើទោះជាយ៉ាងនេះក្ដី នៅក្នុងក្របខណ្ឌគតិយុត្តពិសេសនៃតុលាការនេះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដាក់បណ្ដឹងទាមទារសំណងផ្លូវចិត្តជា

00893583



**ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងសម្រេច÷**

**ថា** មរណភាពរបស់ជនជាប់ចោទ អៀង សារី មានអានុភាពរលត់បណ្តឹងអាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទ អៀង សារី នៅចំពោះមុខ អ.វ.ត.ក។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

---

សមូហភាព ជំនួសមុខ ឱ្យបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ (*សូមមើល* វិធាន ២៣, ២៣ *ស្ទួន*, ២៣ *ស្ទួន២* , ២៣ *ស្ទួនបួន*)។ ការសម្រេចលើបណ្តឹងទាមទារសំណងនេះអាស្រ័យលើការផ្តន្ទាទោសជនជាប់ចោទ (វិធាន ២៣ *ស្ទួនបួន*(១) នៃវិធានផ្ទៃក្នុង)។ ហេតុដូច្នេះ ការរលត់បណ្តឹងអាជ្ញានៅ អ.វ.ត.ក ក៏ចាំបាច់ត្រូវបញ្ចប់បណ្តឹងរដ្ឋប្បវេណីផងដែរ។